**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ព្រឹទ្ធសភា**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែតុលា ឆ្នាំ២០២៤

នៅក្នុងខែតុលា ឆ្នាំ២០២៤ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១-សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា

- បានបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទី ចំនួន១លើក។

### ១.១.១-សកម្មភាពចូលរួមកិច្ចប្រជុំ

- បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១លើក និងបើកសម័យប្រជុំលើកទី២ នីតិកាលទី៥ព្រឹទ្ធសភា ចំនួន១លើក។

### ១.១.២-បដិសណ្ឋារកិច្ចភ្ញៀវជាតិ-អន្តរជាតិ

- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** បានអនុញ្ញាតឱ្យឯកឧត្តម **ចាង យ៉ុងហ្គន** (Jang Yun Gon) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។
- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ចំនួន៤លើក រួមមាន៖
  - **ឯកឧត្តម កាត់ស៊ូហ៊ីរ៉ូ ស៊ីណូហារ៉ា** (Katsuhiro Shinohara) ប្រធានតំណាងមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា នៅវិមានព្រឹទ្ធសភា។
  - **ឯកឧត្តម គ្រីស្ទង់ ឡឺសែរី** (Christian Lechervy) ឯកអគ្គរដ្ឋទូត និងជាប្រេសិតពិសេសបារាំង សម្រាប់សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា នៅវិមាន៧មករា។
  - **ឯកឧត្តម ឈី ឈីងសាន** (Qu Qingshan) សមាជិកគណៈកម្មាធិការមជ្ឈិមបក្ស និងជាប្រធានវិទ្យាស្ថានប្រវត្តិសាស្ត្របក្ស និងអក្សរសាស្ត្រ នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន នៅវិមាន៧មករា និង
  - **ឯកឧត្តម ស៊ិនឡាវ៉ង់ ឃុតផៃធូន** (Sinlavong Khoutphaythoune) ប្រធានរណសិរ្សអភិវឌ្ឍន៍ជាតិឡាវ នៅវិមាន៧មករា។

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

### ១.១.៣-សកម្មភាពចូលរួមពិធីផ្សេងៗ

- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** បានអញ្ជើញចូលរួមក្នុងពិធីនានា នៅរាជធានីភ្នំពេញ ចំនួន៣លើក រួមមាន៖
    - បានអញ្ជើញចូលរួមថ្វាយព្រះរាជដំណើរ**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងចូលរួមកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី១៩ នៅទីក្រុងប៉ារីស នៃសាធារណរដ្ឋបារាំង នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
    - បានអញ្ជើញទទួលព្រះរាជដំណើររបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងនិវត្តន៍ពីការចូលរួមកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី១៩ នៅទីក្រុងប៉ារីស នៃសាធារណរដ្ឋបារាំង នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និង
    - បានអញ្ជើញនាំយកនូវគ្រឿងសក្ការបូជា បច្ច័យ ទេយ្យទាន និងគ្រឿងឧបភោគ ប្រគេនព្រះសង្ឃ ចំនួន២៥០អង្គ នៅវត្តមុនីសុវណ្ណ (ហៅវត្តចំពុះក្អែក)។
- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** បានអញ្ជើញចូលរួមក្នុងពិធីនានា នៅរាជធានីភ្នំពេញ ចំនួន៤លើក រួមមាន៖
    - បានអញ្ជើញចូលរួមព្រះរាជពិធីសាសនាខួបលើកទី២០ព្រះវស្សា នៃការគ្រងព្រះបរមសិរីរាជសម្បត្តិរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង។
    - បានអញ្ជើញក្នុងព្រះរាជពិធីមហាមីទ្ទិញខួបលើកទី២០ព្រះវស្សា នៃការគ្រងព្រះបរមសិរីរាជសម្បត្តិរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះពន្លាកិត្តិយសខាងលើព្រះទីនាំងចន្ទច្ឆាយា។
    - បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព**ឯកឧត្តម ជា ចាន់តូ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិ នៃកម្ពុជា នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និង
    - បានអញ្ជើញប្រទានភ្លើងបូជាសព**ឯកឧត្តម ជា ចាន់តូ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិ នៃកម្ពុជា នៅបរិវេណមុខវត្តបទុមវតី រាជធានីភ្នំពេញ។

### ១.១.៤-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន២៨ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន៥៧ច្បាប់។

## ១.២-ឯកឧត្តម ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា

- បានទទួលភារកិច្ចជាប្រធានស្ដីទីព្រឹទ្ធសភា ចំនួន១លើក។

### ១.២.១-បដិសណ្ឋារកិច្ចទ្វេភាគីជាតិ-អន្តរជាតិ

- បានអនុញ្ញាតឱ្យ**ឯកឧត្តម ឈី ឈីងសាន** (Qu Qingshan) សមាជិកគណៈកម្មាធិការមជ្ឈិមបក្ស និងជាប្រធានវិទ្យាស្ថានប្រវត្តិសាស្ត្របក្ស និងអក្សរសាស្ត្រ នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន និងគណៈប្រតិភូ ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ នៅវិមានព្រឹទ្ធសភា និង
- បានអញ្ជើញអមសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យ**ឯកឧត្តម ស៊ិនឡាវង់ ឃុតផៃធូន** (Sinlavong Khoutphaythoune) ប្រធានរណសិរ្សអភិវឌ្ឍន៍ជាតិឡាវ ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ។

### ១.២.២-បេសកកម្មក្រៅប្រទេស

- បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជាទៅបំពេញទស្សនកិច្ចការងារ នៅព្រឹទ្ធសភានៃសាធារណរដ្ឋបារាំង និងសភាតំណាងរាស្ត្រ នៃប៊ុរីក្សត្រលុចសំបួ ហើយក្នុងឱកាសនោះដែរ **ឯកឧត្តមអនុប្រធានទី១** បាន៖
    - ជួបពិភាក្សាការងារជាមួយ**ឯកឧត្តម** Loïc Hervé អនុប្រធានព្រឹទ្ធសភាបារាំង ទទួលបន្ទុកកិច្ចសហប្រតិបត្តិការអន្តរសភា និងក្រុមអន្តរសភាមិត្តភាព ។
    - ជួបពិភាក្សាការងារជាមួយ**ឯកឧត្តម** Hilarion ETONG ប្រធាន APF នៅទីស្នាក់ការសភាប្រើភាសាបារាំង។
    - ជួបពិភាក្សាការងារជាមួយ**ឯកឧត្តម** André REICHARDT អនុប្រធានក្រុមសភាជាតិបារាំង នៃសភាប្រើភាសាបារាំង សមាជិកក្រុមស្រាវជ្រាវហ្វ្រង់កូហ្វូនី អនុប្រធានគណៈកម្មការកិច្ចការអឺរ៉ុប និងជាលេខាគណៈកម្មការច្បាប់រដ្ឋធម្មនុញ្ញ នីតិកម្ម ការបោះឆ្នោត បទបញ្ញាផ្ទៃក្នុង និងរដ្ឋបាលទូទៅ នៃព្រឹទ្ធសភាបារាំង។
    - ជួបពិភាក្សាការងារជាមួយ**លោក** Christophe-André FRASSA អនុប្រធានគណៈកម្មការច្បាប់រដ្ឋធម្មនុញ្ញ នីតិកម្ម ការបោះឆ្នោត បទបញ្ញាផ្ទៃក្នុង និងរដ្ឋបាលទូទៅ នៃព្រឹទ្ធសភាបារាំង ។
    - ជួបពិភាក្សាការងារជាមួយ**ឯកឧត្តម** Marc THEWES ប្រធានក្រុមប្រឹក្សារដ្ឋ នៃប៊ុរីក្សត្រលុចសំបួ នៅព្រឹទ្ធសភាប៊ុរីក្សត្រលុចសំបួ។
    - ជួបពិភាក្សាការងារជាមួយ**លោកស្រី** Edith STEIN ទីប្រឹក្សាជាន់ខ្ពស់ទទួលបន្ទុកកិច្ចការអន្តរជាតិ មជ្ឈិមបូព៌ា អាស៊ីអាគ្នេយ៍ នៃសភាពាណិជ្ជកម្ម នៃប៊ុរីក្សត្រលុចសំបួ នៅព្រឹទ្ធសភាប៊ុរីក្សត្រលុចសំបួ។
    - ជួបពិភាក្សាជាមួយ**លោក** Fabrice ROBERT អគ្គនាយកទទួលបន្ទុកនីតិកម្ម និងត្រួតពិនិត្យរបស់ព្រឹទ្ធសភា នៃប៊ុរីក្សត្រលុចសំបួ។
    - ទទួលជួបពិភាក្សាការងារជាមួយ**លោក** Philippe DELIVET ប្រធាននាយកដ្ឋានទំនាក់

ទំនងអន្តរជាតិ និងពិធីការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបារាំង នៅព្រឹទ្ធសភាបារាំង។

- ជួបពិភាក្សាការងារ និងសិក្សាស្វែងយល់អំពីការប្រព្រឹត្តទៅ នៃសម័យប្រជុំ និងនីតិវិធីសភាបារាំងជាមួយ**លោកស្រី** Marion JOLIVET ប្រធាននាយកដ្ឋានសម័យប្រជុំពេញអង្គនៅព្រឹទ្ធសភាបារាំង។
- អញ្ជើញចូលរួមទទួលទានអាហារថ្ងៃត្រង់ការងារជាមួយ**លោក** Éric TAVERNIER អគ្គលេខាធិការព្រឹទ្ធសភាបារាំង។
- អញ្ជើញចូលរួមទទួលទានអាហារថ្ងៃត្រង់ការងារជាមួយ**លោក** Vincent ÉBLÉ ប្រធានក្រុមអន្តរសភាមិត្តភាពបារាំង-កម្ពុជា និង
- អញ្ជើញចូលរួមទទួលទានអាហារថ្ងៃត្រង់ការងារជាមួយ**ឯកឧត្តម** Michel WOLTER អនុប្រធានព្រឹទ្ធសភា នៃបុរីក្សេត្រលុចសំបួ។

### ១.២.៣-សកម្មភាពចូលរួមប្រជុំ និងពិធីផ្សេងៗ

- បានអញ្ជើញប្រជុំជាមួយគណៈប្រតិភូអមដំណើរដើម្បីពិនិត្យលើកម្មវិធី និងឯកសារពាក់ព័ន្ធនៃដំណើរទស្សនកិច្ចការងារ នៅព្រឹទ្ធសភានៃសាធារណរដ្ឋបារាំង និងសភាតំណាងរាស្ត្រនៃបុរីក្សេត្រលុចសំបួ។
- បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ**ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** នៅមណ្ឌបតម្កល់ព្រះបរមរូប សួនច្បារខាងកើតវិមានឯករាជ្យ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីថ្វាយព្រះពរ**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ក្នុងឱកាសព្រះរាជពិធីខួបទី២០ នៃការគ្រងព្រះបរមសិរីរាជសម្បត្តិ នៅព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីមហាមីទ្ទិញខួបទី២០ នៃការគ្រងព្រះបរមសិរីរាជសម្បត្តិ នៅព្រះពន្លាកិត្តិយសខាងលើព្រះទីនាំងចន្ទច្ឆាយា។
- បានអញ្ជើញចូលរួមក្នុងពិធីអបអរសាទរខួប២០ឆ្នាំ នៃកម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខា ភ្នំពេញ។
- បានអញ្ជើញចូលរួមក្នុងកម្មវិធី Cocktail Reception របស់មជ្ឈមណ្ឌលខ្មែរសិក្សាកិច្ចការតំបន់ (CCRS) និងស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារ Fairfield Marriott ។
- បានអញ្ជើញចូលរួមទទួលទានអាហារថ្ងៃត្រង់ការងារ នៅនិវេសនដ្ឋានស្ថានទូតបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា។
- បានអញ្ជើញចូលរួមពិធីបូជាសព**ឯកឧត្តមនាយឧត្តមសេនីយ៍ សែម សុវណ្ណនី** អនុប្រធានទី១ គណៈកម្មាធិការជាតិសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ អនុប្រធានទី២ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីន និងជា

អគ្គនាយកមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម នៅបរិវេណមុខវត្តបទុមវតី។

- បានអញ្ជើញចូលរួមរំលែកទុក្ខ និងគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តម ជា ចាន់តូ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិនៃកម្ពុជា នៅគេហដ្ឋាននៃសព ក្នុងសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមរំលែកទុក្ខ និងគោរពវិញ្ញាណក្ខន្ធសព**ឧបាសិកា ប៊ួយ ហ៊ាន** ម្តាយបង្កើត**លោក អ៊ី ឆភីរុណ** ប្រធាននាយកដ្ឋានគ្រប់គ្រងអគារ សារពើភណ្ឌ និងសំណង់ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅគេហដ្ឋាននៃសព ក្នុងសង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមរំលែកទុក្ខ និងគោរពវិញ្ញាណក្ខន្ធសព**កញ្ញា សេង ច័ន្ទវណ្ណា** កូនស្រីបង្កើត**លោក សេង ដឿន** ចៅសង្កាត់ស្ពានថ្ម នៅគេហដ្ឋាននៃសព ក្នុងសង្កាត់ស្ពានថ្ម ខណ្ឌកំបូល រាជធានីភ្នំពេញ។

### ១.២.៤-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

- បានចុះហត្ថលេខាលើសេចក្តីសម្រេច ចំនួន១ច្បាប់ និង
- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន៧១ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន១៥ច្បាប់។

## ១.៣-ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី២ព្រឹទ្ធសភា

### ១.៣.១-សកម្មភាពចូលរួមកិច្ចប្រជុំ

- បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១លើក និងសម័យប្រជុំលើកទី២ព្រឹទ្ធសភា ចំនួន១លើក។
- បានអញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមការងារ នៃសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ នៅបន្ទប់ប្រជុំរបស់ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា។

### ១.៣.២-បេសកកម្មក្រៅប្រទេស

- បានអញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃសភាកម្ពុជា ចូលរួមមហាសន្និបាតសហភាពអន្តរសភា លើកទី១៤៩ (IPU-149th) និងកិច្ចប្រជុំពាក់ព័ន្ធក្រោមមូលបទ "ការប្រើប្រាស់វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ សម្រាប់អនាគតប្រកបដោយសន្តិភាព និងចីរភាពកាន់តែប្រសើរ" នៅទីក្រុងហ្សឺណែវ ដោយមានការអញ្ជើញចូលរួមពីសមាជិកសភាជុំវិញពិភពលោកប្រមាណចំនួន៦៣០រូប នៃ១៣០ប្រទេស ហើយក្នុងឱកាសនោះផងដែរ **ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា** បាន៖
  - អញ្ជើញចូលរួមថ្លែងសុន្ទរកថាលើប្រធានបទ "ការប្រើប្រាស់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រាប់អនាគតប្រកបដោយសន្តិភាព និងចីរភាពកាន់តែប្រសើរ"
  - ជំនួបទ្វេភាគី ជាមួយភាគីបរទេស៖

- **ឯកឧត្តម អ៊ីនយុង លី** (In-Young LEE) ប្រធានគណៈប្រតិភូសភា នៃសាធារណរដ្ឋកូរ៉េ។
- **ឯកឧត្តម ធៀន ស៊ីជុន** (Tian Xuejun) ប្រធានគណៈប្រតិភូ នៃសភាចិន។
- **ឯកឧត្តម យុឈិអ៊ិ អាគីរ៉ា** (YOSHII Akira) ប្រធានគណៈប្រតិភូ នៃព្រឹទ្ធសភាជប៉ុន និង
- **លោកជំទាវបណ្ឌិត ទូលៀ អេកសិន** (Dr. Tulia Arkson) ប្រធាន IPU និងជាប្រធានសភាតង់ហ្សានៀ។

១.៣.៣-សកម្មភាពចូលរួមពិធីផ្សេងៗ

- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីថ្វាយព្រះពរ**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ក្នុងឱកាសព្រះរាជពិធីខួបទី២០ នៃការគ្រងព្រះបរមសិរីរាជសម្បត្តិ នៅព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីមហាមីទ្ទិញខួបទី២០ នៃការគ្រងព្រះបរមសិរីរាជសម្បត្តិ នៅព្រះពន្លាកិត្តិយសខាងលើព្រះទីនាំងចន្ទច្ឆាយា។
- បានដឹកនាំផ្តើមធ្វើពិធីបុណ្យកឋិនទានសាមគ្គី ដើម្បីដង្ហែទៅវេរប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់កាលត្រីមាស ក្នុងពុទ្ធសីមាវត្តនិគ្រោធធម្មាសុខារាម ហៅវត្តអន្លង់ជ្រៃ នៅឃុំច្បារអំពៅ ស្រុកបាធាយ ខេត្តកំពង់ចាម។
- បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសព**ឯកឧត្តមនាយឧត្តមសេនីយ៍ សែម សុវណ្ណនី** អនុប្រធានទី១ គណៈកម្មាធិការជាតិសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ អនុប្រធានទី២ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីន និងជាអគ្គនាយកមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម ដែលបានទទួលមរណភាព។
- បានអញ្ជើញចូលរួមអម**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** គោរពវិញ្ញាណក្ខន្ធសព**ឯកឧត្តម ជា ចាន់តូ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិ នៃកម្ពុជា នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និង
- បានអញ្ជើញចូលរួមអម**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ក្នុងពិធីបូជាសព **ឯកឧត្តម ជា ចាន់តូ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិ នៃកម្ពុជា នៅបរិវេណមុខវត្តបទុមវតី។

១.៣.៤-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

- លិខិតថ្វាយព្រះពរ**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចំនួន១ច្បាប់។
- លិខិតថ្លែងអំណរគុណ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ចំនួន ១ច្បាប់។

- លិខិតរំលែកទុក្ខ ចំនួន១ច្បាប់។
- ចុះហត្ថលេខាលើលិខិតស្នើយោបល់ ចំនួន១២ច្បាប់។
- ពិនិត្យលើឯកសារចូល ចំនួន២៥ច្បាប់ និង
- ឯកសារស្រាវជ្រាវ-វិភាគព័ត៌មាន ចំនួន៣៥ច្បាប់។

## ២-សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន១លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ដើម្បី៖

១- ពិនិត្យ និងសម្រេចលើរបាយការណ៍សង្ខេបស្តីពី លទ្ធផល និងសកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី១ និងលើកទី២ នីតិកាលទី៥។

២- កំណត់កាលបរិច្ឆេទ របៀបវារៈ និងសមាសភាពលេខាធិការសម័យប្រជុំព្រឹទ្ធសភាលើកទី២ នីតិកាលទី៥ និង

៣- ផ្សេងៗ

## ៣-សម័យប្រជុំពេញអង្គព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកសម័យប្រជុំលើកទី២ នីតិកាលទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ដើម្បីស្តាប់របាយការណ៍សង្ខេបរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពី លទ្ធផល និងសកម្មភាពការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី១ និងលើកទី២ នីតិកាលទី៥។

## ៤-គណៈកម្មការនានារបស់ព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភាបានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៤.១-មុខងារតំណាង

- បានទទួលពាក្យបណ្តឹង ចំនួន២បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន៦បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង ចំនួន៨បណ្តឹង តម្កល់ទុកមិនចាត់ការ ចំនួន៣បណ្តឹង ធ្វើកំណត់បង្ហាញពាក្យបណ្តឹង ចំនួន៨បណ្តឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធ ចំនួន១បណ្តឹង។
- បានអញ្ជើញចូលរួមអបអរសាទរខួបលើកទី៣១ នៃទិវាប្រកាសរដ្ឋធម្មនុញ្ញ ២៤ កញ្ញា និងព្រះរាជពិធីសម្ពោធវិមានរដ្ឋធម្មនុញ្ញ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅសួនច្បារខាងលិចវិមានឯករាជ្យ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមអបអរសាទរពិធីសំណេះសំណាល និងបំពាក់កន្សែងយុវជនកាកបាទក្រហមកម្ពុជា មកពីគ្រឹះស្ថានឧត្តមសិក្សា ២៥ ក្នុងរាជធានីភ្នំពេញ ចំនួន៤,៧៤២នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា និង**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង

**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** អនុប្រធានអចិន្ត្រៃយ៍កាកបាទក្រហមកម្ពុជា នៅមណ្ឌលសន្និបាត និងអន្តរជាតិជ្រោយចង្វារ រាជធានីភ្នំពេញ។

- បានអញ្ជើញចូលរួមថ្វាយកម្រងផ្កាគោរពព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** គម្រប់ខួប១២ឆ្នាំ ដឹកនាំដោយ**ឯកឧត្តម ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា** នៅមណ្ឌបតម្កល់ព្រះបរមរូប សួនច្បារខាងកើតវិមានឯករាជ្យ រាជធានីភ្នំពេញ។
- បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមបេសកកម្មសិក្សាអាស៊ីរបស់ប្រទេសបារាំង ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅឃុំត្របែក ស្រុកកំចាយមារ ខេត្តព្រៃវែង។
- បានអញ្ជើញចូលរួមវេទិកាកិច្ចប្រជុំពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល នៅស្រុកព្រះស្តេច និងស្រុកកំពង់ត្របែក ខេត្តព្រៃវែង ស្រុកស្វាយជ្រុំ និងក្រុងស្វាយរៀង ខេត្តស្វាយរៀង។
- បានអញ្ជើញចូលរួមជូន និងទទួលដំណើរ**ឯកឧត្តម ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា** អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជាទៅបំពេញទស្សនកិច្ចការងារនៅព្រឹទ្ធសភា នៃសាធារណរដ្ឋបារាំង និងសភាតំណាងរាស្ត្រ នៃបុរីក្សត្រលុចសំបួ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
- បានអញ្ជើញចូលរួមជូន និងទទួលដំណើរ**ឯកឧត្តម អ៊ុច បូរិទ្ធ អនុប្រធានទី២ព្រឹទ្ធសភា** អញ្ជើញដឹកនាំគណៈប្រតិភូសភាកម្ពុជា ចូលរួមមហាសន្និបាតសហភាពអន្តរសភា លើកទី១៤៩ (IPU-149th) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន៤លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា រួមមានៈ ពិធីអបអរសាទរខួប២០ឆ្នាំ នៃកម្ពុជា ចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO), ពិធីបើកការដ្ឋានសាងសង់អគារមេជ្ឈមណ្ឌលកណ្តាល អគារចំណត រោងជាង និងអគារវេជ្ជសាស្ត្រស៊ីក្លូត្រុង នៃមន្ទីរពេទ្យកាល់ម៉ែត, ពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣០ឆ្នាំ ថ្ងៃបង្កើតកងពលតូចលេខ៧០ (១៥ តុលា ១៩៩៤-១៥ តុលា ២០២៤) និងពិធីបិទការប្រកួតកីឡាយុទ្ធគុនចម្រុះខ្មែរបុរាណ នៅរាជធានីភ្នំពេញ និង
- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន យុវជន យុវនារី ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ស្វែងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយនានា ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានី និងតាមបណ្តាខេត្តនានា ចំនួន៨០លើក

ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ ចំនួន១៥៦លើក។

## ៤.២-កិច្ចសហប្រតិបត្តិការអន្តរជាតិ

សមាជិក សមាជិកាព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្មក្នុងការងារសហប្រតិបត្តិការអន្តរជាតិរបស់ព្រឹទ្ធសភា ជាពិសេសទំនាក់ទំនងក្នុងកម្រិតតំបន់ និងអន្តរជាតិ និងទទួលបានលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

- **ឯកឧត្តម ជី ច័ន្ទ្រផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញទៅចូលរួមមហាសន្និបាតសហភាពអន្តរសភាលើកទី១៤៩ (IPU-149th) និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។
- **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី "កិច្ចការសង្គម និងវប្បធម៌ នៃសភាតំបន់អាស៊ី (APA)" នៅទីក្រុងម៉ូស្គូ សហព័ន្ធរុស្ស៊ី។
- **ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរទិវាបុណ្យជាតិ នៃសាធារណរដ្ឋកូរ៉េ នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញភូគីត្រា។
- **ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា បានយាងចូលរួមពិធីបុណ្យថ្ងៃ នៃការរួបរួម នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នៅលើនាវាទេសចរណ៍ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
- **ឯកឧត្តមបណ្ឌិត ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា៖
  - បានអញ្ជើញចូលរួមសន្និសីទអន្តរជាតិ ស្តីពីការបំលាស់ទីរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសហ្វ្រង់កូហ្វូន (La mobilité citoyenne francophone pour la création, l'innovation et l'entrepreneuriat) ដែលបានរៀបចំដោយសភាប្រើភាសាបារាំង (APF) សហការជាមួយទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (Agence française de développement AFD) ដើម្បីប្រមូលយោបល់ និងអនុសាសន៍ជូនប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ដែលចូលរួមកិច្ចប្រជុំកំពូលអង្គការអន្តរជាតិប្រើភាសាបារាំងលើកទី១៩ នៅក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គម ទីក្រុងប៉ារីស នៃសាធារណរដ្ឋបារាំង។
  - បានអញ្ជើញចូលរួមកិច្ចប្រជុំអំពីវឌ្ឍនភាពការងារជាមួយអនុគណៈកម្មការរៀបចំមហាសន្និបាតសន្និសីទអន្តរជាតិ នៃបណ្តាគណបក្សនយោបាយនៅអាស៊ី លើកទី១២ (ICAPP-12th) និងកិច្ចប្រជុំពាក់ព័ន្ធ ដើម្បីត្រៀមរៀបចំមហាសន្និបាតសន្និសីទអន្តរជាតិ នៃបណ្តាគណបក្សនយោបាយនៅអាស៊ី លើកទី១២ (ICAPP-12th) ដែលមានសមាសភាពចូលរួម ចំនួន៧០នាក់ នៅវិមានព្រឹទ្ធសភា។
  - បានអញ្ជើញជួបពិភាក្សាការងារជាមួយលោក Andrew McDOWELL អគ្គនាយក នៃធនាគារវិនិយោគអឺរ៉ុប ដែលមានទីតាំងនៅបុរីក្សេត្រលុចសំបួ។

- បានអញ្ជើញដឹកនាំសមាជិក សមាជិកាគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា អញ្ជើញទទួលទានអាហារការងារពេលល្ងាច តាមសេចក្តីអញ្ជើញរបស់**ឯកឧត្តម Gusty GRAAS** តំណាងរាស្ត្រ និងជាប្រធានគណៈកម្មការកិច្ចការបរទេស អឺរ៉ុប កិច្ចសហប្រតិបត្តិការ អន្តោប្រវេសន៍ និង **Grande région** នៃសភាតំណាងរាស្ត្រនៃបុរីក្សេត្រលុចសំបួ ដោយមានការអញ្ជើញចូលរួមផងដែរពីសមាជិក សមាជិកា នៃគណៈកម្មការកិច្ចការបរទេសមួយចំនួនទៀត តំណាងឱ្យគណបក្សខុសៗគ្នា នៃសភាតំណាងរាស្ត្រនៃបុរីក្សេត្រលុចសំបួ។
- បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំជាមួយ**ឯកឧត្តម សួស យ៉ារ៉ា** ប្រធានគណៈកម្មការទី៥រដ្ឋសភា ដើម្បីពិភាក្សាការងារអំពីការរៀបចំកិច្ចប្រជុំអន្តរសភាអាស៊ាន (ASEAN Inter-Parliamentary Assembly – AIPA) នៅទីក្រុងវៀងច័ន្ទន៍ ប្រទេសឡាវ នៅវិមានព្រឹទ្ធសភា។
- បានអញ្ជើញទទួលជួប**លោក Ivan KABACOFF** អ្នករៀបចំកម្មវិធីតុមូលស្តីពី ភាពរំកិលនៃអនាគត៖ ចរាចរក្នុងកន្លែងនិយាយភាសាបារាំងរបស់សិស្ស បុគ្គលហាត់ការកូនជាង និងបុគ្គលស្ម័គ្រចិត្តវ័យក្មេង នៅក្នុងសន្និសីទរៀបចំដោយ APF តាមរយៈ Video Conference នៅរាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមកិច្ចប្រជុំត្រៀមលក្ខណៈចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន លើកទី៤៥ (45th AIPA General Assembly) ដែលនឹងប្រព្រឹត្តទៅនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានរដ្ឋសភា។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីលៀងសាយភោជន៍ រៀបចំដោយ**ឯកឧត្តម ផាក ជុងវុក** (Park Jung-Wook) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋកូរ៉េ និង**លោកជំទាវ** ដើម្បីអបអរសាទរទិវាបុណ្យជាតិ នៃសាធារណរដ្ឋកូរ៉េ នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា។

- **ឯកឧត្តមបណ្ឌិត ចែម វីឡាំ** ប្រធានក្រុម **ឯកឧត្តម ម៉ាន់ ឈឿន** អនុប្រធាន **លោកជំទាវ មុំ សណ្តាប់** សមាជិកា និង**ឯកឧត្តម សត ណាឌី** សមាជិក នៃក្រុមមិត្តភាពព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជាជាមួយក្រុមប្រឹក្សាសហព័ន្ធ នៃសភាសហព័ន្ធ នៃសហព័ន្ធរុស្ស៊ី បានទទួលជួបពិភាក្សាការងារជាមួយ**ឯកឧត្តម Anatoly Borovik** ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅបន្ទប់ប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា អគារE ជាន់ទី១។
- **លោកជំទាវបណ្ឌិត ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា និងជាអនុប្រធានក្រុមអន្តរសភា អាស៊ាន(AIPA) **ឯកឧត្តម អាយ ខន** អនុប្រធានគណៈកម្មការ និងជាសមាជិកក្រុមអន្តរសភាអាស៊ាន(AIPA) បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំដើម្បីត្រៀមលក្ខណៈចូលរួមកិច្ចប្រជុំរវាងថ្នាក់ដឹកនាំអាយប៉ា លើកទី៤៥ (AIPA-45th) ជាមួយប្រមុខដឹកនាំអាស៊ាន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប អនុប្រធានទី១រដ្ឋសភា** និងជាប្រធានក្រុមរដ្ឋសភាកម្ពុជា នៃស្ថាប័នអន្តរសភា នៃអន្តរសភាអាស៊ាន។

- **ឯកឧត្តម ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និង**លោកជំទាវ មុំ សណ្តាប់** សមាជិកាគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញអមដំណើរគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា ទៅបំពេញទស្សនកិច្ចការងារនៅព្រឹទ្ធសភាបារាំង និងសភាតំណាងរាស្ត្រលុចសំបួ ដើម្បីបន្តពង្រឹងកិច្ចសហប្រតិបត្តិការ និងលើកកម្ពស់ការងារការទូតសភា ដែលស្របទៅតាមចក្ខុវិស័យរបស់ព្រឹទ្ធសភា នីតិកាលទី៥ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តម ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា** និងជាប្រធានក្រុមមិត្តភាពកម្ពុជា-បារាំង ហើយជាអនុប្រធានសភាប្រើភាសាបារាំង និងជាប្រធានគណៈប្រតិភូ។
- **ឯកឧត្តម អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអនុញ្ញាតឱ្យ**លោក ណាកាសិ កិនស៊ូកិ** (Nagase Kensuke) អគ្គទីប្រឹក្សាស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ជួបសវនាការការងារ នៅបន្ទប់ឯកឧត្តមប្រធាន អគារF ព្រឹទ្ធសភា។
- **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** ប្រធានក្រុម **ឯកឧត្តម ខៀវ មុត** អនុប្រធាន **ឯកឧត្តម អ៊ុក គង់** សមាជិក និង**ឯកឧត្តម ឡាន់ ឆន** សមាជិក នៃក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជា-ជប៉ុន បានអញ្ជើញជួបពិភាក្សាការងារ និងទទួលទានអាហារថ្ងៃត្រង់ ជាមួយ**ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី** (UENO Atsushi) ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅស្ថានទូតជប៉ុន រាជធានីភ្នំពេញ។
- **ឯកឧត្តម គង់ មុនីកា** សមាជិកគណៈកម្មការ១ព្រឹទ្ធសភា បានអញ្ជើញចូលរួមកម្មវិធី International Visitor Leadership Program (IVLP) ក្រោមប្រធានបទ **"Not Too Young to Run"** នៅសហរដ្ឋអាមេរិក។
- **ឯកឧត្តម សុក ហាច** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីប្រារព្ធខួបទិវាឯកភាពជាតិអាល្លឺម៉ង់លើកទី៣៤ នៅនិវេសនដ្ឋានឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ រាជធានីភ្នំពេញ។

ថ្ងៃសុក្រ ៦ កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០២៤

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី១**

**អ៊ុច បូររិទ្ធ**